ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វេយ្យាករណ៍ខ្មែរ

## សម្រាប់គ្រប់ភូមិសិក្សា

ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ

| -ា -ិ -ី -ឹ -ឺ -ុ -ូ -ួ េ- េ-ឿ

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

រៀបរៀងដោយ
**ឆន់ ហ៊ិន**
អតីតសាស្ត្រាចារ្យ ម.ស.ប.ភ. ភាសាបារាំង

ត្រឹមត្រូវតាមក្បួនដើម,តាមវចនានុក្រម,តាមភាសាជាក់ស្ដែង

ព.ស. ២៥៥៥ រក្សាសិទ្ធិគ្រប់យ៉ាង គ.ស. ២០១១

# ជីវប្រវត្តិសង្ខេប



លោក **ឆន់ ហ៊ិន** កើតថ្ងៃទី ៧ កញ្ញា ១៩៤៥ ក្នុងឃុំជាងទង ស្រុកត្រាំកក់, តាកែវ; រៀននៅសាលាបឋមសិក្សាបំពេញវិជ្ជាអង្គរកា ដើមទសវត្ស ១៩៥០; បន្តការសិក្សាមធ្យមសិក្សានៅវិទ្យាល័យព្រះឧទ័យ ក្រុងតាកែវ; គ្រូបំពេញវិជ្ជានៅកណ្តាលទសវត្ស ១៩៦០; និស្សិតសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិផ្នែកភាសាបារាំង នៅដើមទសវត្ស ១៩៧០ ; បង្រៀនភាសាបារាំងនៅវិទ្យាល័យសន្តិភាព នៃក្រុងកំពង់ស្ពឺ ពីឆ្នាំ ១៩៧៣ ដល់ ១៩៧៥ ។ រស់នៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ។

ចូលធ្វើការនៅក្រសួងការបរទេស ក្នុងខែឧសភា ឆ្នាំ ១៩៧៩ ។ ខែតុលាឆ្នាំដដែល ចេញទៅធ្វើជាអ្នកការទូតនៅទីក្រុងម៉ូស្គូ នៃសហភាពសូវៀត និងជួយបើកការិយាល័យព័ត៌មាន ក្រុងស្តុកខុល្ម នៃព្រះរាជាណាចក្រស៊ុយអែដ ។ ខែវិច្ឆិកា ឆ្នាំ១៩៨០ ធ្វើជាអ្នកការទូតនៅក្រុងញូវដែល្ហី នៃសាធារណរដ្ឋឥណ្ឌា ដល់ឆ្នាំ១៩៨៣ ; ចូលរួមជាញឹកញាប់ក្នុងគណៈប្រតិភូសាធារណរដ្ឋប្រជាមានិតកម្ពុជាទៅបំពេញបេសកកម្មនៅបរទេស ។ ពីខែតុលា ១៩៩២ បំពេញការងារការទូតនៅ អ.ស.ប. ក្រុងញូវយ៉កនិងនៅទីក្រុងវ៉ាស៊ិងតោនឌីស៊ី នៃ ស.រ.អា. ពីឆ្នាំ ១៩៩៤ ដល់ ១៩៩៥ ។ បំពេញបេសកកម្មការទូតនៅសហពន្ធ័រុស្ស៊ី ពីឆ្នាំ ២០០៤ ដល់ ២០០៧ ; ចូលនិវត្តន៍នៅដំណាច់ឆ្នាំ ២០០៨ ។

ចូលចិត្តអាន វប្បធម៌អារ្យធម៌ឥណ្ឌា-ខ្មែរ និង អក្សរសាស្ត្របារាំង ។ អាចនិយាយបានភាសា បារាំង, អង់គ្លេស, អេស្ប៉ាញ៉ុល, ព័រទុយហ្គាល់ ។ ស្គាល់និងយល់បានខ្លះភាសា ថៃ, រុស្ស៊ី, អ៊ីតាលី, វៀតណាម ។

# ជំពូក ៤

# ខណ្ឌសញ្ញា

**និយមន័យ.-** ខណ្ឌសញ្ញា គឺជាសញ្ញាទាំងឡាយដែលគេប្រើនៅក្នុងប្រយោគ ឬនៅក្នុងអត្ថបទ សម្រាប់សម្គាល់លក្ខណៈច្រើនយ៉ាង ដូចជា ការបញ្ចប់សេចក្តីក្នុងឃ្លា ឬក្នុងប្រយោគ, ការបង្គាប់ឱ្យអានបានត្រឹមត្រូវទៅតាមបរិបទ, ការចោទសួរ, ការពន្យល់សេចក្តីបន្ថែមនៅក្នុងឃ្លា, ការកត់សម្គាល់អ្វីដែលគេយល់ថាមានសារៈសំខាន់, ការបន្លឺសំឡេងចេញថ្នមៗ ឬខ្លាំងៗ, ការកត់សម្គាល់នូវការប្តូរយោបល់គ្នា ជាដើម ។

ពិតមែនតែខណ្ឌសញ្ញាខ្លះយើងចម្លងពីភាសាអឺរ៉ុបក៏ដោយ ក៏ប៉ុន្តែការប្រើប្រាស់មិនមែនដូចគ្នាសុទ្ធសាធទាំងអស់ទេ ។ មុននឹងភាសាអឺរ៉ុបចូលមកដល់ខ្មែរយើងមានប្រើប្រាស់ខណ្ឌសញ្ញាផ្ទាល់ខ្លួនជាច្រើនរួចទៅហើយ ។ ក្នុងភាសាខ្មែរមានខណ្ឌសញ្ញាខ្លះដែលមិនមានក្នុងភាសាអឺរ៉ុប និងខណ្ឌសញ្ញាអឺរ៉ុបខ្លះដែលមិនមានក្នុងភាសាខ្មែរ ។ ខណ្ឌសញ្ញានិងការប្រើប្រាស់របស់វា មានដូចតទៅ ៖

## ១.កណ្តកសញ្ញា ឬ ក្បៀស (,)

គេប្រើសញ្ញាក្បៀសសម្រាប់ញែកពាក្យឱ្យដាច់ស្រឡះចេញពីគ្នា នៅក្នុងប្រយោគណាដែលមានការរៀបរាប់ពាក្យជានាមក្តី ជាគុណនាមក្តី ឬជាកិរិយាសព្ទក្តី ។ ក្នុងករណីនេះ ការប្រើក្បៀសក្នុងភាសាខ្មែរក៏មានតម្លៃដូចគ្នានឹងការប្រើក្បៀសនៅក្នុងភាសាអឺរ៉ុបដែរ ។ ឧទាហរណ៍ ៖



### *ក/ ប្រើជាមួយសាធារណនាម*

នៅក្នុងប្រទេសកម្ពុជា មានឈើប្រណីតជាច្រើន ដូចជា គគីរ, បេង, នាងនួន, ធ្នង់, សុក្រំ, តាត្រាវ, ជើងចាប, កកោះ; រីឯឈើស៊ីផ្លែវិញមានដូចជា ក្រឡាញ់, ពង្រ, ជន្លួស, កញ្ចើបាយដាច, ព្រីង, អំព្រំ, ទ្រៀល, មាក់ប្រេង, គុយ, មាក់ប្រាង, វាយ, ពោន ជាដើម ។

### *ខ/ ប្រើជាមួយអសាធារណនាម*

នៅក្នុងប្រទេសកម្ពុជា ខេត្តដែលជាប់ព្រំដែនជាមួយប្រទេសជិតខាងគឺ : ខេត្តបាត់ដំបង, ពោធិ៍សាត់, ឧត្តរមានជ័យ, ព្រះវិហារ, ស្ទឹងត្រែង, រតនគិរី, មណ្ឌលគិរី, ក្រចេះ, កំពង់ចាម, ព្រៃវែង, ស្វាយរៀង, តាកែវ និង កំពត ។

និស្សិតដែលប្រឡងជាប់អាហារូបករណ៍មានឈ្មោះដូចតទៅ ៖

ជា សម្បត្តិ, ខាត់ សេង, កេង កុមារ រង្សី, កញ្ញា សំ ម៉ាលីភួង, សួង ចិន្តា, កញ្ញា ចេង សុវណ្ណរត្ន, តិម ហាក់ សេង លី, រស់ ពិន, អេង ញ៉ា, ស ចេវ, ឡេវ សុខ អេង សាយ, ស៊ិត សុផាន, ឆាយ អ៊ាម ម៉េង ជូ, កញ្ញា វង់ បុប្ផាវណ្ណៈ ។

### *គ/ ប្រើជាមួយគុណនាម*

ក្រុមហ៊ុននេះទទួលភារៈសង់អាគារមួយយ៉ាងធំ, ខ្ពស់, ទំនើប, ស្អាត ហើយបន្ទប់នីមួយៗត្រូវឱ្យទូលាយ, ស្រឡះ, មានរចនាបទខុសៗគ្នា, មានខ្យល់ធម្មជាតិបក់ចេញចូលបានស្រួលផង ។

គាត់ជាបុរសម្នាក់ដ៏សង្ហា, ស្រស់, ក្លាហាន, ខ្លាំង ហើយវាងវៃផង ។

### *ឃ/ ប្រើជាមួយកិរិយាសព្ទ*

នៅនាសម័យអង្គរ ព្រះមហាក្សត្រិយ៍ខ្មែរដ៏មានបុណ្យបារមីទាំងឡាយ ទ្រង់ដឹកនាំនគរកម្ពុជាឱ្យបានស្គាល់ការរីកចម្រើនយ៉ាងខ្លាំង ដូចជា លើវិស័យ

សេដ្ឋកិច្ច ព្រះអង្គឱ្យកសាងបារាយណ៍, ជីកព្រែក, ជីកស្រះ, លើកទំនប់, លើកផ្លូវ, សង់ស្ពាន និង រក្សាសម្បត្តិធម្មជាតិ ។

**សម្គាល់ :** ចំពោះករណីពីរចុងក្រោយ គឺចំណុច **ឥ** និង **ឃ** ជួនកាលមានមតិខ្លះយល់ថា មិនចាំបាច់ប្រើក្បៀសទេ គឺគ្រាន់តែដកឃ្លាទៅ វាស្មើនឹងក្បៀសទៅហើយ ។ ប៉ុន្តែយើងយល់ថា ការប្រើក្បៀស វាប្រសើរជាង ដោយហេតុថា ក្នុងការវាយអង្គុលីលេខ ជួនកាលគេមិនបានដកឃ្លាឱ្យបានត្រឹមត្រូវទេ មិនតែប៉ុណ្ណោះ មានកន្លែងខ្លះដែលគេមិនត្រូវដកឃ្លា គេបែរជាដកឃ្លា ឯកន្លែងដែលត្រូវដកឃ្លា គេបែរជាមិនដកឃ្លាទៅវិញ ។ ម្យ៉ាងទៀត នៅក្នុងវចនានុក្រមខ្មែរ ក្នុងប្រយោគខ្លះ លោកប្រើក្បៀសផង ដកឃ្លាផង ត្រង់កន្លែងដែលគេត្រូវដកឃ្លា គឺប្រើដូចក្នុងភាសាបារាំងដែរ ។ យើងយល់ថា នេះប្រហែលជាការភ្លាំងភ្លាត់ជាប់តពីការបោះពុម្ពលើកមុនៗមក ហើយលោកមិនបានពិនិត្យនិងកែឱ្យអស់ ដោយសារខ្វះពេលវេលា ដូចលោកមានចារឹកទុកស្រាប់ ។

តាមធម្មតា នៅក្នុងប្រយោគខ្មែរ យើងតែងដកឃ្លានៅទីណាដែលនៅក្នុងប្រយោគបារាំង គេប្រើក្បៀស និងនៅទីណាដែលគេត្រូវអានដោយទម្លាក់សំឡេង រួចបង្អង់មួយភ្លែត ។ ការធ្វើដូច្នេះអាចឱ្យន័យក្នុងប្រយោគបានច្បាស់ ហើយអ្នកស្តាប់ក៏អាចយល់ន័យបានច្បាស់ល្អដែរ ។ ឧទាហរណ៍ ៖

នៅនាសម័យបុរាណដ៏យូរលង់ នៅក្នុងប្រទេសទាំងឡាយណាដែលមានព្រះមហាក្សត្រិយ៍គ្រប់គ្រង វប្បធម៌និងអារ្យធម៌ដ៏សែនរុងរឿងតែងកើតមានឡើងនៅក្នុងប្រទេសទាំងនោះ ហាក់បីដូចជាទេព្តាប្រទានឱ្យ ។

ប្រសិនបើគេអានជាប់គ្នារដឹកជារហូត ឥតមានការលើកដាក់ ឬបង្អង់សំឡេង ឬបើគេសរសេរប្រយោគដោយបន្តពាក្យជាប់គ្នារហូត ប្រយោគនោះនឹងមិនពីរោះស្តាប់ អ្នកស្តាប់អាចមិនយល់ន័យឬអាចច្រឡំន័យថែមទៀតផង ។



បើត្រូវរៀបរាប់អសាធារណនាមបន្តគ្នាវិញ គេមិនអាចកត់សម្គាល់នរណាជានរណាឱ្យពិតប្រាកដបានទេ ។ ឧទាហរណ៍ ៖

នៅពេលអាម៉ែនយកបាយទៅជូនម្តាយអាសយនៅឯវត្តវាទើបនឹងមកដល់ពីសាលារៀនរួចចូលរួមប្រគេនភត្តាហារចំពោះព្រះសង្ឃទាំងអស់គ្នា ។

និស្សិតឆ្នើមទាំងនោះមានឈ្មោះដូចតទៅ :

ហាក់ សេង លី លីវ ម៉េង ឡុង សូ សេដ្ឋា មណី សិរិត សុខា សេង សិរីវិសុទ្ធ សំ សុខា សួង បុប្ផា វណ្ណនី រស់ សេង គិម លៀង ។ល។

## ២. ចំណុចក្បៀស (;)

គេប្រើចំណុចក្បៀសនៅក្នុងប្រយោគ សម្រាប់ញែកការរៀបរាប់អ្វីៗឱ្យទៅតាមពួក តាមក្រុមរបស់វា ឬសម្រាប់ញែកប្រយោគទោលខ្លីៗ ដែលគេចង់ឱ្យបន្តគ្នា ដោយមិនបាច់ប្រើខណ្ឌសញ្ញា ដើម្បីចៀសវាងការប្រើប្រយោគទោលខ្លីៗច្រើនពេក ឬ/និង ដើម្បីភ្ជាប់ការប្រើបរិបទរួមគ្នា ។ ឧទាហរណ៍ ៖

ព្រៃភ្នំដ៏ធំហើយវែងនោះជាជម្រកនៃសត្វជាច្រើនប្រភេទ ក្នុងនោះ ពួកឧរង្គសត្វមានដូចជា អណ្តើក, កង្កែប, កំប្រុក, ពស់, ថ្លាន់, ពង្រូល, កាំប្រមា; ពួកសត្វចតុប្បាទមានជាអាទិ៍ ដំរី, ខ្លា, ខ្ទីង, ទន្សោង, ស្វា, ទោច, ប្រើស, ក្តាន់, ទន្សាយ, ឈ្លូស, រមាំង; ឯបក្សាបក្សីមានដូចជា ត្មាត, ចចាត, ត្រយង, ត្រដក់, ស្មោញ, ស្ទាំង, រនាល, ពពេច, ពពូល, ល្វាចេក, តាវ៉ៅ, ស្វិតចៅ ជាដើម ។

ព្រះរាជាទ្រង់រៀបចំទ័ពឱ្យត្រៀមប្រយុទ្ធ តាមក្បួនពិជ័យសង្គ្រាម គឺកងទ័ពដឹកនាំដោយឧកញ៉ាវង្សាអគ្គរាជកែវ មានគ្នា ១.៥០០ នាក់ជាទ័ពមុខ; កងទ័ពដឹកនាំដោយឧកញ៉ាចក្រីសួស មានគ្នា ១.០០០ នាក់ ជាទ័ពឆ្វេង ; កង

ទ័ពដឹកនាំដោយឧកញ៉ាយោមរាជម៉ី មានគ្នា ១.០០០ នាក់ ជាទ័ពស្តាំ ; កងទ័ពដឹកនាំដោយឧកញ៉ាក្រឡាហោមម៉ែតមានគ្នា ១.០០០ នាក់ នៅខាងក្រោយជាទ័ពស្មៀង ; ចំណែកឯព្រះបរមបពិត្រជាអម្ចាស់ជីវិត ទ្រង់ការពលចំនួន ១.០០០ នាក់ ជាទ័ពកណ្តាល ។

ពីម្សិលមិញ ឪពុកខ្ញុំទៅទិញគោស្វាវពីគេមួយនឹម ; ថ្ងៃនេះ គាត់យកគោនោះទៅពង្រាប ; ស្អែក គាត់ទៅវត្តជាមួយជីដូនខ្ញុំ ; ឯជីតាខ្ញុំវិញ គាត់នៅផ្ទះដើម្បីត្បាញចង្អេរមួយបង្ហើយ ។

រាល់ព្រឹក ខ្ញុំក្រោកពីដេកនៅម៉ោងប្រាំកន្លះ ; ខ្ញុំហាត់ប្រាណ ងូតទឹករួច ស្រស់ស្រូប ; ដល់ម៉ោងប្រាំពីរទើបខ្ញុំចេញទៅសាលារៀន ។

## ៣. ទ្វិពិន្ទុលេខ ( ៖ )

ខណ្ឌសញ្ញានេះមានការប្រើដូចតទៅ ៖

**ក/** សម្រាប់ដាក់នៅចុងបញ្ចប់នៃប្រយោគ ដែលបន្តដោយការកត់ត្រាសម្តីផ្ទាល់របស់មនុស្ស ហើយការកត់ត្រាសម្តីនេះត្រូវដាក់នៅក្នុងសញ្ញាអញ្ញ-ប្រកាស “......” (មើលទំព័រ ៦០-៦៣) ។ ឧទាហរណ៍ ៖

ឪពុកចៅសេកបាននិយាយប្រាប់ចៅសេកថា ៖ "កាលឪនៅរៀន ឪត្រូវដើរចម្ងាយប្រាំមួយគីឡូម៉ែត្រទាំងទៅទាំងមក ប៉ុន្តែសប្បាយណាស់ ព្រោះមានគ្នាច្រើន សុទ្ធតែវេចបាយកញ្ចប់រៀងៗខ្លួន" ។

ពូសននិយាយថា ៖ "ស្អែកនេះ ខ្ញុំទៅលេងកំពង់សោមដែរ" ។

**ខ/** សម្រាប់ដាក់នៅខាងចុងប្រយោគណាដែលត្រូវបន្តដោយការរៀបរាប់សេចក្តីផ្សេងៗជាបន្តគ្នា ក្នុងបន្ទាត់ដាច់ៗគ្នា ។ ឧទាហរណ៍ ៖

ពុទ្ធបរិស័ទត្រូវប្រតិបត្តិនូវបញ្ចសីល ឬសីលទាំងប្រាំ ដែលបង្គាប់បញ្ជា



ឱ្យវៀរចាកនូវអំពើអាក្រក់នានា ដូចតទៅ ៖

១. បាណាតិបាតា គឺការសម្លាប់សត្វ ;
២. អទិន្នាទាន គឺការលួចទ្រព្យគេ ;
៣. មុសាវាទ គឺការនិយាយកុហកវ ;
៤. កាមេសុមិច្ឆាចារ គឺការចាប់រំលោភកូនប្រពន្ធគេ ;
៥. សុរាមេរយ គឺការសេពនូវគ្រឿងស្រវឹង ។

***សម្គាល់.–*** គេមិនត្រូវច្រឡំសញ្ញាទ្វិពិន្ទុលេខ (៖) ជាមួយនឹងវណ្ណយុត្តិយុគលពិន្ទុ(ះ)ទេ ។ សព្វថ្ងៃ មានការប្រើយុគលពិន្ទុតាមបែបដូចគ្នានឹងភាសាអឺរ៉ុបជាជំនួសទ្វិពិន្ទុលេខ ដោយមកពីហ្វុនលីម៉ូន(Font Limon) ដែលគេនិយមប្រើជាងគេគ្មានសញ្ញានេះ ។ គេអាចប្រើសញ្ញានេះបាននៅបន្ទាប់ពាក្យដែលត្រូវពន្យល់ ឬបន្តដោយការរៀបរាប់ ប៉ុន្តែក្នុងករណីនេះ គេត្រូវដាក់វាឱ្យឃ្លាតពីអក្សរខាងចុងបន្តិច ដើម្បីកុំឱ្យច្រឡំជាមួយយុគលពិន្ទុ ពីព្រោះយុគលពិន្ទុគេត្រូវអានឱ្យចេញសព្ទជា អាក់ ឬ អ៊ាក់ (ពេញមាត្រា) ។ ឧទាហរណ៍ ៖

**<u>កម្មវត្ថុ</u>** : អំពីការស្នើសុំអាហារូបករណ៍សម្រាប់សិស្សពូកែ
**<u>យោង</u>** : លិខិតរបស់ក្រសួងអប់រំ យុវជន និង កីឡា លេខ... ចុះថ្ងៃទី ..

អាចប្រើនៅក្នុងការពន្យល់ពាក្យ ។ ឧទាហរណ៍ ៖

**អភិជ្ឈា** : សេចក្តីលោភលន់ខ្លាំង. ការសម្លឹងចង់បានទ្រព្យរបស់គេ ។ អភិជ្ឈាជាជំងឺផ្នែកចិត្តសាស្ត្រមួយដែលគេមិនអាចព្យាបាលឱ្យសះជាបាន ។
**អវិជ្ជា** : មិនយល់ឬមិនស្គាល់ឬក្សត់ករណីយកិច្ចរបស់ខ្លួន. មោហ៍បាំង ។

ម្យ៉ាងទៀត មានការខុសឆ្គងជាច្រើនលើការប្រើសញ្ញាចុចពីរនេះ កាលណាគេជួបពាក្យ "**ថា**" ជានិបាតសព្ទ ប្រើជាមួយកិរិយាសព្ទឯទៀតៗ ។ ពាក្យ

"**ថា**" ប្រើជាមួយកិរិយាសព្ទនានា ដូចជា **និយាយថា, ពោលថា, ប្រាប់ថា, ទ្រង់ត្រាស់ថា, ជឿលថា, ទាយថា,** ។ល។ គឺជានិបាតសព្ទ ដែលស្មើនឹងពាក្យបារាំងថា "que" និងពាក្យអង់គ្លេសថា "that" កាលណាគេត្រូវសរសេរពាក្យបន្តក្នុងប្រយោគដើម្បីកត់ត្រាសម្ដីមិនផ្ទាល់ (style indirect)។ ប៉ុន្តែបើគេចង់កត់ត្រាសម្ដីនិយាយផ្ទាល់ ឬសម្ដីចំៗរបស់អ្នកនិយាយវិញ (style direct) នោះ ទើបគេប្រើទ្វិពិន្ទុលេខ ឬ ចុចពីរនេះ ។ ឧទាហរណ៍ ៖

លោកម៉ុកនិយាយថា ៖ "កូនខ្ញុំខំរៀនណាស់ ; វារៀនពូកែជាងគេ" ។ (នេះជាការកត់សម្ដីចំៗ ដែលគេត្រូវតែដាក់ក្នុងសញ្ញា អញ្ញប្រកាស "...") ។

បើជាការកត់សម្ដីមិនចំៗវិញ គេត្រូវថា ៖

លោកម៉ុកនិយាយថា កូនគាត់ខំរៀនណាស់ ហើយថា វារៀនពូកែជាងគេ ។ លោកគ្រូផ្ដាំថា ស្អែកគាត់មិនបានមកបង្រៀនទេ ។ (គេមិនត្រូវដាក់សញ្ញាទ្វិពិន្ទុលេខ ឬចុចពីរ នៅបន្ទាប់ពាក្យ "ថា" នេះទេ) ។

## ៤.បុច្ឆនសញ្ញា ( ? )

ជាសញ្ញាដែលគេប្រើសម្រាប់សម្គាល់ការចោទសួរ ហើយតែងដាក់នៅចុងក្រោយប្រយោគសួរជានិច្ច ។ អាស្រ័យលើបរិបទ ប្រយោគសួរក្នុងភាសាសរសេរអាចវែងឬខ្លី ឬតែមួយពាក្យក៏មាន ។ ប្រយោគសួរតែងប្រើជាមួយនឹងពាក្យសួរផ្សេងៗ ដូចជា តើ, ឬ, ឬទេ, ទេឬ, ប៉ុន្មាន, ដូចម្ដេច(បានជា), ព្រោះអ្វី(បានជា), ហេតុម្ដេច(ក៏ ឬ បានជា), ហេតុដូចម្ដេច(ក៏ ឬ បានជា), ហេតុអ្វី(ក៏ ឬ បានជា), យ៉ាងម៉េចក៏, យ៉ាងម៉េច, អ្វី(ទៅ), អីគេ, អង្កាល់, កាលណា, ណា ជាដើម ។



ពាក្យសម្រាប់សួរអាចនៅខាងចុងប្រយោគក៏បាន អាចនៅដើមប្រយោគឬដើមឃ្លា ក៏បាន ឬនៅខាងដើមផងខាងចុងផងក៏បាន ជួនកាលគេមិនចាំបាច់ប្រើពាក្យសួរ គឺគ្រាន់តែដាក់សញ្ញាសួរ (បុច្ឆនសញ្ញា)ក៏បាន ។ ឧទាហរណ៍ ៖

តើប្រាសាទដ៏ធំៗស្កឹមស្កៃពីជំនាន់បុរាណ គេសង់របៀបម៉េច?
ព្រោះអ្វីបានជាគេនៅតែបន្តបំផ្លាញសម្បត្តិធម្មជាតិអ៊ីចឹង?
ហេតុអ្វីបានជាគេត្រូវតែនាំគ្នាថែរក្សាព្រៃឈើនិងសត្វព្រៃ?
ឯងយំអី? នឹកម៉ែ? យកនំមួយឬ? យកអាធំ? ម៉េចទៅ?
ឯងថាទៅលេងអង្គរវត្ត? ទៅអង្កាល់? អត់ទេ? ចុះបងឯង?
ថ្ងៃនេះ ឯងមិនទៅរៀនទេឬ? ឯងទៅមើលកុនជាមួយអញឬទេ?
ប្រាសាទអង្គរវត្តសង់ក្នុងរជ្ជកាលក្សត្រិយ៍អង្គណា?

### សម្គាល់

បរិបទក្នុងប្រយោគសួរតែមួយអាចខុសគ្នា ទៅតាមសម្ដីដែលអ្នកសួរបន្លឺឡើង គឺអាចមានន័យជា ការស្រឡាញ់ថ្នាក់ថ្នម, ការសម្លុត, ការខឹងសម្បា, ក្នុងស្ថានភាពធម្មតា, ភាពជិតស្និទ្ធ ។ ប៉ុន្តែ មានពាក្យសួរខ្លះអាចឱ្យបរិបទខុសគ្នា ដោយអាស្រ័យលើការដាក់វានៅខាងចុងឬខាងដើមប្រយោគ ។

ចូរប្រៀបធៀបបរិបទនៃប្រយោគសួរពីរដូចខាងក្រោមនេះ ៖

អង្កាល់បានឯងទៅរៀន? និង ឯងទៅរៀនអង្កាល់?

តាមទម្លាប់នៃភាសាខ្មែរ អ្វីដែលគេឧទានចេញមកមុន គឺគេចាត់ទុកថាសំខាន់ជាង ។ ដូច្នេះ ចំពោះប្រយោគសួរទាំងពីរខាងលើនេះ ក្នុងប្រយោគទីមួយ អ្នកសួរយកចិត្តទុកដាក់លើ **ពេលវេលា** ; ឯក្នុងប្រយោគសួរទីពីរវិញ អ្នកសួរយកចិត្តទុកដាក់លើ **ការទៅរៀន** ជាងលើពេលវេលា ។

## ៥.ឧទានសញ្ញា ( ! )

គេប្រើឧទានសញ្ញាសម្រាប់ដាក់នៅខាងចុង ជាប់ពាក្យ ឬឃ្លា ឬប្រយោគណាមួយ ដើម្បីសម្គាល់ការបញ្ចេញសំឡេងខ្លាំងៗ បញ្ជាក់ពីការភ្ញាក់ផ្អើល. ការភ័យអាសន្ន. ការខ្លាច. បញ្ជាដាច់អហំការ. ការសម្បូងសង្រ្វូង. ការស្រែកជយឃោស. ការគំរាម ជាដើម ។ ឧទាហរណ៍ ៖

ជយោ! ព្រះរាជាណាចក្រកម្ពុជា!

សូមទេព្តាជួយថែរក្សាព្រះបិតាឯករាជ្យជាតិ!

ឱ! ព្រះជាម្ចាស់ខ្ញុំអើយ! សូមទ្រង់ព្រះមេត្តាដល់ពួកយើងខ្ញុំផង!

ហ៏! យកក្រមានេះទៅផ្លាស់ងូតទឹកទៅ! ចេញទៅឱ្យឆាប់!

ឯងនេះក្បាលរឹងណាស់! ពីថ្ងៃនេះទៅ ប្រុងខ្លួនឱ្យមែនទែន ណ៎ា!

### សម្គាល់

**ក/** ជានិច្ចកាល គេតែងប្រើសញ្ញានេះជាមួយពាក្យ ឱ. អើយ. នុ៎ះ. ហ្ន៎. ហ៏. អុញ. នែ. ណ៎ា. អូយ. ចុំ. ។ល។

**ខ/** នៅក្នុងប្រយោគជាសំណួរលាយនឹងកំហឹងខ្លាំង ជួនកាលគេប្រើបុច្ឆនសញ្ញាផង ឧទានសញ្ញាផង ។ ឧទាហរណ៍ ៖

ហេតុម៉េចក៏ឯងមិនព្រមឈប់លេងល្បែងស៊ីសង?!

ហិនហោចទ្រព្យរបស់អស់ហើយ នៅមិនទាន់ភ្ញាក់ភ្នែកទេឬ ឯង?! ។

## ៦. អញ្ញប្រកាស ( “ ... ” )

ជាសញ្ញាឃ្នាបម្យ៉ាង មានរាងប្រហាក់ប្រហែលនឹងវង់ក្រចកតូចៗ ។ គេតែងដាក់វានៅខាងលើបន្ទាត់សរសេរធម្មតា តែមិនឱ្យខ្ពស់ហួសអក្សរពេកទេ ។ សញ្ញានេះជាគំនូសកោងបួន គឺសញ្ញាបើកពីរ និងសញ្ញាបិទពីរប្រឈមស្របគ្នាពីលើចុះក្រោម សញ្ញាបើកមានក្បួចខាងក្រោមបន្តិច ឯសញ្ញាបិទមានក្បួចខាងលើបន្តិច ។ គេប្រើសញ្ញានេះសម្រាប់ ៖



**ក/** តាបសម្តីនិយាយ ដែលគេត្រូវកត់ត្រាដោយត្រង់ៗជាលាយលក្ខណ៍អក្សរ ។ ឧទាហរណ៍ ៖

បន្ទាប់ពីមេឃុំកាត់ក្តីឱ្យគាត់ចាញ់ ពូម៉ែនតវ៉ា ដោយនិយាយថា ៖

“ខ្ញុំមិនសុខចិត្តទេ ខ្ញុំត្រូវតែប្តឹងទៅសាលាដំបូងទៀត” ។

**ខ/** តាបការដកស្រង់សម្តីឆ្លើយឆ្លងគ្នា ឬការពិភាក្សាគ្នា រវាងមនុស្សពីរនាក់ ។ ក្នុងករណីនេះ កាលណាមនុស្សម្នាក់និយាយចប់ គេត្រូវដាក់សញ្ញាខណ្ឌមួយ រួចចុះបន្ទាត់ដើម្បីកត់ត្រាសម្តីរបស់មនុស្សម្នាក់ទៀត ដោយចាប់ផ្តើមជាមួយនឹងរជ្ជុសញ្ញា (មើលពាក្យនេះនៅទំព័រ ៤៣) ។ ឧទាហរណ៍ ៖

ក្នុងពេលផ្លាស់ប្តូរទស្សនៈគ្នារវាងពិននិងសយ ពិនលើកឡើងថា ៖

“តើកិត្តិយសរបស់មនុស្សអាស្រ័យលើអ្វី តាមឯងយល់?

- កិត្តិយសអាស្រ័យលើចំណេះវិជ្ជាផ្សំនឹងគតិបណ្ឌិត ព្រោះថាមានចំណេះវិជ្ជាមិនទាន់មានន័យថាមានគតិបណ្ឌិតទេ ។ ចុះឯងវិញ ឯងយល់យ៉ាងម៉េច?

- អញយល់ថា មានតែទ្រព្យសម្បត្តិទេ ដែលធ្វើឱ្យមនុស្សមានសេចក្តីថ្លៃថ្នូរនិងមានកិត្តិយស ព្រោះថា កាលណាគេមានទ្រព្យសម្បត្តិច្រើន ឬមានលុយច្រើន គេអាចធ្វើអ្វីៗបានទាំងអស់ ។

- ត្រូវហើយក្នុងករណីដែលទ្រព្យសម្បត្តិនោះបានមកដោយអំពើសុចរិត ប៉ុន្តែ បើជាទ្រព្យបានមកពីអ្វីមួយមិនប្រក្រតី គ្មានតម្លាភាព វាជាទ្រព្យចោកទាប មិនអាចឱ្យមានកិត្តិយសកើតទេ ហើយវាក៏ជាគ្រូម្នាក់ដ៏អាក្រក់ទៀតផង ។

- អ៊ីចឹងមានតែឯងឱ្យតម្លៃតែទៅលើគតិបណ្ឌិតទេឬ?

- ហ្នឹងហើយ! បើមានចំណេះវិជ្ជាហើយខ្វះគតិបណ្ឌិត មនុស្សមិនអាចមានសេចក្ដីថ្លៃថ្នូរកើតទេ ទោះបីនៅដកដង្ហើម ក៏គេទុកដូចជាស្លាប់ដែរ" ។

**ឥ/** តាមការដកស្រង់សម្ដីផ្ទាល់មួយផ្នែកបញ្ចូលក្នុងប្រយោគពិពណ៌នា ដើម្បីបញ្ជាក់ពីការពិតហើយសំខាន់នៃសម្ដីនោះ ។ ឧទាហរណ៍ ៖

មេគណបក្សប្រឆាំងបានសម្ដែងឱ្យឃើញការបន្ធូរបន្ថយនូវឥរិយាបថតឹង-តែងរបស់ខ្លួន ដោយអះអាងថា "ខ្ញុំនឹងខិតខំជួយគណបក្សឈ្នះឆ្នោតឱ្យអស់ពីសមត្ថភាពក្នុងការស្ដារសេដ្ឋកិច្ច ជាអាទិ៍គឺហេដ្ឋារចនាសម្ព័ន្ធ" ហើយលោកបន្តថា លោកនឹងស្ថិតនៅជាដៃគូរបស់គណបក្សឈ្នះឆ្នោតវិញ ។

**ឃ/** តាមពាក្យ ឬ អក្សរ ដោយឡែកណាមួយ ដែលគេយល់ថាសំខាន់ ហើយចង់ឱ្យអ្នកអានចាប់អារម្មណ៍លើផង ។ ឧទាហរណ៍ ៖

ក្នុងសម័យនៃប្រទេសឥណ្ឌាបុរាណ **"វេយ្យាករណ៍"** ជាវិទ្យាសាស្ត្រមួយដែលគេរៀនដាច់ដោយឡែកពីភាសា ។

ពាក្យ "កួរស្រូវ" គេសរសេរនឹងអក្សរ "ក" មិនមែនសរសេរនឹង អក្សរ "គ" ទេ ; ឯពាក្យ "គួរសម" ទើបសរសេរនឹងអក្សរ "គ" ។

ពាក្យថា "ស្លាប់" ចំពោះព្រះមហាក្សត្រិយ៍ទ្រង់រាជ្យ គេត្រូវថា "សោយព្រះទិវង្គត"; ចំពោះព្រះមហាក្សត្រិយានីជាព្រះអគ្គមហេសី គេត្រូវថា "សោយព្រះវិលាល័យ"; ចំពោះព្រះអង្គម្ចាស់ គេត្រូវថា "ក្ស័យព្រះជន្ម" ។

មនុស្សគ្រប់រូបត្រូវយល់ថា "ហិរិឱត្តប្បៈ" គឺសេចក្ដីខ្មាសបាប និងសេចក្ដីខ្លាចបាប ជាគុណសម្បត្តិមួយដ៏ឧត្ដុង្គឧត្ដមសម្រាប់ខ្លួន ។

**ង/** តាមពាក្យ ឬសេចក្ដីនៃការពោលអះអាងណា ដែលអ្នកនិពន្ធឬអ្នកកត់ត្រាចង់បញ្ជាក់ថា អាចមានអ្នកខ្លះថាត្រឹមត្រូវដូចការពោល ឯអ្នកខ្លះទៀតថាមិនមានការស្មោះត្រង់ដូចការពោលនោះទេ ។ ឧទាហរណ៍ ៖



នៅក្នុងអង្គប្រជុំនៃអ្នកដឹកនាំកំពូល១របស់រដ្ឋាភិបាល លោករដ្ឋមន្ត្រីមានប្រសាសន៍ថា លោកបានបំពេញការងារក្នុងភាព "យុត្តិធម៌ជាទីបំផុត" ថែមទាំងសុខចិត្តបរិច្ចាគទ្រព្យសម្បត្តិ "ផ្ទាល់ខ្លួន" អស់ជាច្រើនដើម្បីបម្រើឱ្យដល់ការអភិវឌ្ឍន៍នៃប្រទេសជាតិ ។

## ៧.អព្ភន្តរសញ្ញា ('...')

សញ្ញានេះជាឃ្នាបម្យ៉ាងទៀត ដែលមានន័យនិងការប្រើប្រាស់ប្រហែលគ្នានឹងសញ្ញាអញ្ញប្រកាសដែរ ប៉ុន្តែមានការប្រើតិចជាង ។ ដូចមានឈ្មោះរបស់វាស្រាប់ ដែលមានន័យថា សញ្ញាដាក់ខាងក្នុង ឬដាក់ក្នុងចន្លោះ ឬដាក់នៅកណ្ដាល គេប្រើសញ្ញានេះសម្រាប់គាបសម្ដីផ្ទាល់របស់មនុស្សម្នាក់ទៅក្នុងសម្ដីផ្ទាល់របស់មនុស្សម្នាក់ទៀត ។ ដូច្នេះ បើមានការប្រើសញ្ញាអញ្ញប្រកាសរួចហើយ អ្វីដែលគេចង់កំណត់ដូចការប្រើអញ្ញប្រកាសធម្មតានោះ គេត្រូវតែដាក់វាគាបនៅក្នុងអព្ភន្តរសញ្ញាវិញ ។ ឧទាហរណ៍ ៖

កុមារពិន ដែលជាសិស្សល្អមួយរូប បាននិយាយប្រាប់គេថា ៖

"ឪពុកខ្ញុំតែងទូន្មានខ្ញុំជារឿយ១ថា 'ឯងត្រូវខំរៀន ទាន់ខ្លួននៅក្មេង'; គាត់បានទិញសៀវភៅល្អ១ឱ្យខ្ញុំ ដោយប្រាប់ខ្ញុំទៀតថា 'ឯងត្រូវតែខិតខំទន្ទេញសុភាសិតខ្មែរឱ្យបានចេះច្រើន ព្រមទាំងឱ្យយល់អត្ថន័យរបស់វាផង' ប៉ុន្តែគាត់ក៏ឱ្យខ្ញុំខំរៀនភាសាបរទេសផងដែរ" ។

***សម្គាល់***

មានការភ័ន្តច្រឡំជាយូរមកហើយអំពីអញ្ញប្រកាសសញ្ញា ("...") និងអព្ភន្តរសញ្ញា ('...') ។ សូម្បីតែនៅក្នុងវចនានុក្រមខ្មែរ ក៏លោកយល់ថាសញ្ញាអញ្ញប្រកាសគឺជាអព្ភន្តរសញ្ញាដែរ ហើយមានតែមួយនេះផង ។ ម្យ៉ាងទៀត នៅក្នុងវចនានុក្រមខ្មែរ ក៏គេមិនឃើញមានពាក្យ "អញ្ញប្រកាស" ដែរ ។

ត្រង់នេះ យើងគួរយល់ថាជាការខ្វះខាតមួយ ដែលយើងត្រូវតែនាំគ្នាជួយបំពេញ ព្រោះសម្ដេចព្រះសង្ឃរាជ ជួន ណាត ទ្រង់បានចារឹកទុកឱ្យយើងដែរថា នៅខ្វះពាក្យច្រើនណាស់ ហើយកាលពីសម័យនោះ ការប្រើសញ្ញាអព្ភន្តរៈ (‘...’) ហាក់ដូចជាមិនទាន់មាននៅឡើយ ។ លោកបានពន្យល់ថា **អព្ភន្តរ** គឺ ខាងក្នុង, ចំកខាងក្នុង, ចន្លោះឬរវាងខាងក្នុង, កណ្ដាល, ទីចំពាក់កណ្ដាល ។ ដូច្នេះន័យនេះឃើញថាត្រូវគ្នាជាមួយនឹងសញ្ញា ‘...’ ដែលត្រូវស៊កនៅកណ្ដាល ។ រីឯអញ្ញប្រកាសវិញ គេមិនដែលស៊កនៅកណ្ដាលទេ តែគេត្រូវដាក់វានៅដើមទី និងទីបញ្ចប់នៃសម្ដីនិយាយ ។ បើយើងមើលក្នុងវចនានុក្រម បារាំង-ខ្មែរ របស់លោក តិប យក់ និង ថាវ គន្ធ យើងនឹងឃើញថា លោកបកប្រែពាក្យបារាំង guillemets ថា "អញ្ញប្រកាស" ដែរ មិនមែនថា "អព្ភន្តរសញ្ញា" ទេ ។

នេះគ្រាន់តែជាការច្រឡំឈ្មោះប៉ុណ្ណោះ ប៉ុន្តែ ការប្រើប្រាស់កន្លងមកមិនមានការខុសឆ្គងទេ ។

## ៨. មច្ឆណ្ឌសញ្ញា ឬ ពងត្រី ( ... )

មច្ឆណ្ឌសញ្ញាកើតឡើងដោយការចុចជាចំណុចបីបន្តគ្នា ប៉ុន្តែក៏អាចមានច្រើនជាងនេះ រហូតដល់ក្លាយទៅជាបន្ទាត់មួយដែរ កាលបើមានការចាំបាច់ត្រូវជំនួសអ្វីវែង ។ គេប្រើមច្ឆណ្ឌសញ្ញាសម្រាប់សម្គាល់ប្រយោគមួយមិនទាន់អស់សេចក្ដី គឺប្រយោគដែលមិនទាន់បានបញ្ចប់ ដោយមកពីមូលហេតុដូចតទៅ ៖

**ក/** មនុស្សម្នាក់និយាយមិនទាន់ចប់ផង ស្រាប់តែម្នាក់ទៀតនិយាយកាត់ ។ ឧទាហរណ៍ ៖

“អញខំធ្វើការសព្វថ្ងៃនេះ គឺដើម្បីសុភមង្គលក្នុងគ្រួសារ ជាពិសេស គឺដើម្បីឱ្យកូនបានរៀនសូត្រ និងឱ្យវា ... ។



- អញក៏អ៊ីចឹងដែរ គ្មានអីធំជាងកូនទេ បើវារៀនបានខ្ពស់ មានចំណេះពេញខ្លួនទៅ យើងក៏លែងពិបាកចិត្ត លែងកើតទុក្ខព្រួយ លែង ... ។
- អើ! វាប្រាកដអ៊ីចឹងហើយ នរណាក៏មានគំនិតដូចតែគ្នាហ្នឹង លើកលែងតែអ្នកនោះមិនចេះគិតវែងឆ្ងាយ ខ្វះការអប់រំ ខ្វះការយល់ដឹង ... ។
- ប៉ុន្តែសង្គមបរិយាកាសមានឥទ្ធិពលធំណាស់លើការអប់រំ ... លើ ...។
- អើ! ... ជាក់ស្ដែងគឺ ... គឺមែនហ្នឹង ណា!” ។

**ខ/** ការនិយាយដោយមិនបញ្ចប់សេចក្ដី ដោយហេតុថា សេចក្ដីដែលត្រូវបញ្ចប់ជាពាក្យគំរាមកំហែង, ជាការជេរប្រមាថឆ្អេះ, ជាពាក្យចំអេសចំអាស, ជាពាក្យប្រទេចផ្ដាសា ឬពុំនោះសោត ជាករណីទាក់ទងនឹងការអៀនខ្មាស ឬដោយសារខ្លាចអ្នកម្ខាងទៀតមិនពេញចិត្ត ជាដើម ។ ឧទាហរណ៍ ៖

ហ៊ឹះ! ធ្វើឱ្យអញអត់មិនបានឥឡូវហើយ! តិចអញ .... ។

បែកបាក់សាមគ្គីកើតពីអាត្មានិយម អយុត្តិធម៌ក៏កើតពី ... ហ្នឹងដែរ ។

ប្រុសធុនអន់ដូចឯងនេះ ហ៊ឹះ! វាសមណាស់តែ ... សមតែ ... ហ៊ឹះ! អញមិនចង់ថាទេ អា! ។

តាំងពីខ្ញុំបានឃើញនាងនោះពេលណាមក ខ្ញុំដូចជា .... ចេះតែ ...។

បា ... បាទទាន ... ខ្ញ... ខ្ញ ... ខ្ញុំ .. ខ្ញុំបាទមិន ... មិន .. បានសម្លាប់មនុស្សនោះទេ តែ ... តែខ្ញុំ ... ខ្ញុំបាទបានទៅជាមួយគេមែន ... បាទ! ។

ទូ ... ទូ ... ទូលព្រះបង្គំ សូម ...សារភាពកំហុស ថ្វ ... ថ្វាយព្រះអង្គ ... ក្រា ... ក្រាប ... ក្រាបទូល! ។

**គ/** កាលណាមានបាត់សេចក្ដីខ្លះនៅក្នុងច្បាប់ដើម ដែលគេចម្លងចេញដើម្បីបោះពុម្ពជាថ្មី ។ ក្នុងករណីនេះ មច្ឆណ្ឌសញ្ញាអាចត្រូវគេធ្វើឡើង ដោយ

ពេញមួយបន្ទាត់តែម្ដង ។ ឧទាហរណ៍ ៖

..........................................................................................

ត្រាស់ទៅព្រះបាទពិម្ពិសារថា មហារាជ នានិម្មិតព្រះអង្គទាំង ៦ ប្រការនោះ គឺត្បូងកែវ ១, គឺដែកភ្លើង១, គឺរាជសីហ:១, គឺត្រុឌរាជ ១, គឺកែវរតនបទុម-រក្សមានរស្មី ១, ពពួកកែវ ...១, នោះមហារាជ ... និម្មិតទាំង៦ប្រការនោះ និងរាជសីហ: ចាំបន្តិចទៅ ត្រុឌរាជនោះហោះចេញទៅទិសបស្ចិម ឱ្យយកក្អែកងក្អែកជាគ្នា ។ លុះព្រះសាសនាបាន ២៣៥៩ ព្រះវស្សា លុះដល់ចុងកន្ទុយហោងនាដើមកន្ទុយនោះ ព្រះសាសនាបាន ៨០០ នោះសុខសប្បាយហោង។[១]

**ឃ/** កាលណាគេកត់ត្រាសម្ដីមិនបានអស់ ព្រោះកត់មិនទាន់ ឬស្ដាប់មិនច្បាស់ ។ បើមានករណីបែបនេះ អ្នកកត់ត្រាមិនត្រូវបន្ថែមពាក្យ ឬសេចក្ដីតាមការយល់ឃើញរបស់ខ្លួនទេ ប៉ុន្តែត្រូវដាក់មច្ឆណ្ឌសញ្ញាវិញ ។ ឧទាហរណ៍ ៖

លោកប្រធានាធិបតីបានគូសបញ្ជាក់ថា លោកសូមចាត់ទុកជាសំខាន់នូវមតិទាំងអស់ដែលសមាជិកគណបក្សប្រឆាំងបានលើកឡើង ព្រមទាំងយល់ព្រមឱ្យផ្ដល់ ....... (ស្ដាប់មិនបាន) ដើម្បីឱ្យគណបក្សប្រឆាំងអាចមានវិធានការជួយកម្ចាត់អំពើពុករលួយ និងអំពើជួញដូរកុមារ និងស្ត្រីភេទផង ។

**ង/** មច្ឆណ្ឌសញ្ញាអាចប្រើសម្រាប់បញ្ចប់ការរៀបរាប់បន្តពាក្យជាច្រើន មានន័យស្រដៀងគ្នា ដែលគេមិនចាំបាច់រៀបរាប់ថែមទៀត ព្រោះអ្នកអានអាចកាត់យល់បាន ។ ក្នុងករណីនេះ មច្ឆណ្ឌសញ្ញាមានន័យប្រហែលគ្នានឹង "ជាដើម" ឬ "។ល។" ដែរ ។ ឧទាហរណ៍ ៖

ដូចគេជ្រាបស្រាប់ហើយ ឈើខ្លឹមនៅប្រទេសយើងគឺ នាងនួន, បេង, កកោះ, ធ្នឹក, សុក្រំ ... ដែលត្រូវទទួលរងការបង្ហិនបង្ហោចស្ទើរអស់ ។

---

១- ពុទ្ធទំនាយ ឥន្ទទំនាយ ។



## ៩. វង់ក្រចក ឬ នខសញ្ញា ((...))

សញ្ញាវង់ក្រចក ឬក៏ហៅម្យ៉ាងទៀតថា នខសញ្ញា មានរាងដូចជាឈ្មោះរបស់វាដែរ គឺមានរាងជារង្វង់ កោងតែបន្តិច ដូចវង់ក្រចកបញ្ឈរ ។ នខសញ្ញាមានការប្រើប្រាស់ដូចតទៅ ៖

**ក/** សម្រាប់គាបពាក្យ ឬឃ្លា ឬសេចក្ដីអ្វីមួយ ដែលមិនមាននាទីអ្វីទាក់ទិនជាមួយនឹងប្រយោគ ប៉ុន្តែគ្រាន់តែមាននាទីនឹងពន្យល់ប្រាប់ដោយឡែកដើម្បីជាការរំឭក ឬការយោង សម្រាប់អ្នកអាន ។ ឧទាហរណ៍ ៖

ប្រយោគកម្រងកែវ (មើលក្នុងរឿង មហាវេស្សន្តរជាតក របស់លោកញ៉ុក ថែម) មានការឃ្លាតចាកពីវេយ្យាករណ៍ខ្លះមែន ប៉ុន្តែវាបង្កើតឱ្យមានសូរសព្ទពីរោះដល់ត្រចៀកនៃអ្នកស្ដាប់ ។

មេដឹកនាំខ្មែរក្រហមឈ្មោះ ប៉ុល ពត (ឈ្មោះដើម សាឡុត ស) និងបក្សពួករបស់វាដែលក្រាស់ដោយអវិជ្ជានិងដោយគំនិតសាហាវព្រៃផ្សៃ បានបញ្ជាឱ្យសម្លាប់ខ្មែរជាអ្នកប្រាជ្ញរាជបណ្ឌិត, មន្ត្រីរាជការ, បញ្ញវន្ត, សិល្បករ, ព្រះសង្ឃ និងប្រជាជនស្លូតត្រង់អស់ជិតបីលាននាក់ (ប្រភពខ្លះថាអស់ជិតពីរលាននាក់) ក្នុងពេលពួកវាកាន់អំណាចពីឆ្នាំ ១៩៧៥ ដល់ចុងឆ្នាំ ១៩៧៨ ។

នៅក្នុងខេត្តសុរិន្ទនៃប្រទេសថៃ (ខេត្តរបស់ខ្មែរពីបុរាណ) គេឃើញមានបេតិកភណ្ឌខ្មែរជាច្រើន ឯប្រជាជននៅទីនោះសុទ្ធតែមានដើមកំណើតជាខ្មែរ; គេនៅតែនិយាយភាសាខ្មែរ ព្រោះជាភាសារបស់ដូនតាគេ ។

យន្តហោះបានចុះចតនៅទីក្រុងម៉ាឌ្រីដ (ប្រទេសអេស្ប៉ាញ) អស់រយៈពេលបីម៉ោង ទើបបន្តដំណើរទៅទីក្រុងប៉ារីស (ប្រទេសបារាំង) ។

**ខ/** សម្រាប់គាបពាក្យដែលគេចង់សរសេរកាត់ បើកាលណាពាក្យពេញត្រូវបានគេសរសេរចេញមករួចហើយ ។ ឧទាហរណ៍ ៖

បន្ទាប់ពីសង្គ្រាមលោកលើកទីពីរត្រូវផុតរលត់ទៅ អង្គការសហប្រជាជាតិ (អ. ស. ប.) ត្រូវបានគេបង្កើតឡើង សម្រាប់ដោះស្រាយបញ្ហាផ្សេងៗក្នុងបំណងរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ ។

**គ/** សម្រាប់គាបពាក្យ ឬ ឈ្មោះជនបរទេស បន្ទាប់ពីគេសរសេរវាជាអក្សរខ្មែររួចហើយ ដើម្បីបញ្ជាក់ការអានឱ្យបានត្រឹមត្រូវ ។ ឧទាហរណ៍ ៖

អង្គការយូណេស្កូ (UNESCO) របស់អង្គការសហប្រជាជាតិ (អ. ស. ប.) បានបើកស្ថានតំណាងរបស់ខ្លួនមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ជនជាតិបារាំងដ៏ល្បីល្បាញ គឺលោក ព្យែរ ឡូទី (Pierre Loti) កើតសេចក្ដីរំភើបនិងកោតស្ញប់ស្ញែងយ៉ាងខ្លាំង នៅពេលដែលលោកបានឃើញប្រាសាទបុរាណរបស់ខ្មែរជាលើកដំបូង (ក្នុងសតវត្សរ៍ទី ១៩) ។

**សម្គាល់**

ក្នុងករណីខ្លះ គេក៏អាចប្រើរជ្ជុសញ្ញា ឬ សញ្ញាក្បៀស ដើម្បីជំនួសការប្រើវង់ក្រចកដែរ ។ ឧទាហរណ៍ ៖

ព្រះបាទអង្គជ័យ -ព្រះបាទត្រសក់ផ្អែម- ទ្រង់សព្វព្រះទ័យឱ្យព្រះអនុជ, ព្រះបាទអង្គសួស្ដិ៍, ឡើងសោយរាជសម្បត្តិ ដោយហេតុថា ព្រះរាជបុត្ររបស់ព្រះអង្គ, ព្រះអង្គម្ចាស់សិរីរតន៍, មានព្រះជន្មនៅក្មេងពេក ។

លោក ស៊ីម៉ុន បូលីវ៉ារ (Simón Bolivar) -ជាមហាវីរបុរសនៃប្រទេសបូលីវី- បានច្បាំងដណ្ដើមយកឯករាជ្យពីពួកអេស្ប៉ាញ៉ុល ។



លោក ទូប៉ាក់ អាម៉ារូ -វីរបុរសនៃប្រទេសប៉េរូ- ដែលបានរើបម្រះប្រឆាំងការត្រួតត្រារបស់ពួកអេស្ប៉ាញ៉ុល ក៏ត្រូវពួកអេស្ប៉ាញ៉ុលសម្លាប់តាមការធ្វើទារុណកម្មទៅ នៅក្នុងខែកុម្ភៈ ឆ្នាំ ១៧៨១ ។

## ១០. វង់តង្កៀប ( [...] )

នៅក្នុងការសរសេរភាសាខ្មែរ គេមិនដែលប្រើសញ្ញាវង់តង្កៀប [...] នេះទេ ដោយមកពីខ្មែរយើងមិនសូវត្រូវការ ។ សញ្ញានេះត្រូវបានយើងចម្លងមកពីភាសាបារាំង ដែលគេប្រើជាពិសេសតែនៅក្នុងការគណនាលេខផ្នែកពីជគណិត (algèbre) ប៉ុណ្ណោះ ។ សូម្បីតែនៅក្នុងភាសាអឺរ៉ុប ទោះបីជាគេប្រើសញ្ញានេះសម្រាប់សម្គាល់ការអានពាក្យ ក៏ក្នុងភាសាខ្មែរយើងមិនមានប្រើដូចគេដែរ គឺយើងប្រើតែវង់ក្រចកប៉ុណ្ណោះ ។ ក្នុងពីជគណិត សញ្ញានេះមានការប្រើដូចគ្នានឹងការប្រើវង់ក្រចកដែរ តែមានលក្ខណៈធំជាង គឺបើមានការប្រើវង់ក្រចកហើយ ហើយគេត្រូវការគាបអ្វីៗនៅក្នុងវង់ក្រចកនោះ គេត្រូវប្រើវង់តង្កៀបនេះ ។ អ្វីៗដែលនៅក្នុងវង់តង្កៀប គេត្រូវគណនាជាមុនសិន រួចទើបគេគណនាអ្វីដែលនៅក្នុងវង់ក្រចកជាក្រោយ ។

## ១១. រ៉ាត់ ឬ ឃ្នាប ( } ឬ { ឬ {...} )

**ក/** នៅក្នុងពីជគណិត ការប្រើ រ៉ាត់ឬឃ្នាប មានន័យដូចគ្នានឹងការប្រើវង់តង្កៀបឬវង់ក្រចកដែរ ។ ក្នុងករណីនេះ គេតែងប្រើរ៉ាត់មួយសម្រាប់បើក ( { ) និងរ៉ាត់មួយទៀតសម្រាប់បិទ ( } ) ទៅ ជា {...} ។

**ខ/** គេប្រើរ៉ាត់បើក ឬ រ៉ាត់បិទ សម្រាប់គាបពាក្យពីរឬច្រើន ដើម្បីសម្គាល់ថា ពាក្យទាំងនោះមានមុខងាររួមគ្នាតែមួយ ។ ឧទាហរណ៍ ៖

ថ្នាំព្យាបាលជំងឺរាំងរដូវត្រូវផ្សំដូចតទៅ ៖

-ខ្ទីទឹក<br>
-ខ្ទីភ្លើង<br>
-ដើមលំពស់ } ស្មោរចូលគ្នាផឹក<br>
-ដើមចេកទុំ

គ/ គេប្រើវ៉ាត់បើកនិងវ៉ាត់បិទ សម្រាប់គាបពាក្យពីរ ឬច្រើន ដែលគេត្រូវអានម្ដងមួយៗ នៅក្នុងប្រយោគដដែលៗ ។ ឧទាហរណ៍ ៖

ធម៌សូត្រដើម្បីបំបាត់ការយល់សប្តិអាក្រក់ ៖

**យន្ទុនិមិត្តំ អវមង្គលញ្ច យោចាមនាបោ សកុណស្សសទ្ទោ**

**បាបគហោ ទុស្សុបិន្នំអកន្តំ { ពុទ្ធា / ធម្មា / សង្ឃា } នុភាវេន វិនាសមេន្តុ**

## ១២. បេយ្យាលៈ ឬ លៈ ( ។ល ។)

ឈ្មោះខណ្ឌសញ្ញានេះ ដែលគេអានពេញតួថា ប៉ៃ-យ៉ា-ឡៈ យើងយកតែសព្ទខាងចុងមកហៅឈ្មោះវា ហើយសរសេរជា "។ល។" យ៉ាងនេះ ។ គេប្រើវាសម្រាប់បំប្រួញសេចក្ដីវែងឱ្យនៅខ្លី ឬច្រើនឱ្យនៅតិច ដោយគេយល់ច្បាស់ថាអ្នកអាន ឬអ្នកស្ដាប់ អាចដឹងសេចក្ដីបន្តទៅទៀតហើយ ឬដឹងថាការរៀបរាប់នោះនៅមិនទាន់អស់ទេ ហើយអ្វីដែលគេមិនបានរៀបរាប់ជាបន្ថែមទៀតនោះអ្នកស្ដាប់អាចកាត់យល់បានទាំងអស់ ។ ឧទាហរណ៍ ៖

ប្រាសាទបុរាណខ្មែរជាច្រើន គឺប្រាសាទអង្គរវត្ត, ប្រាសាទបាយ័ន, ប្រាសាទបន្ទាយស្រី, ប្រាសាទបន្ទាយឆ្មារ, ប្រាសាទព្រះគោ, ប្រាសាទភិមានអាកាស, ប្រាសាទព្រះខ័ន, ។ល។ ជាប្រភពចំណូលដ៏សំខាន់នៃថវិការដ្ឋ ។



ដើមឈើសំខាន់ៗនៅក្នុងព្រៃភ្នំនេះមាន បេង, នាងនួន, គគីរ, ខ្លុង, ត្បែង, តាត្រាវ, ម៉ៃសាក់, ជើងចាប, ត្រាច, ធ្នុង, ។ល។

**សម្គាល់ :** ក្នុងករណីដែលគេចង់បង្ហាញថា អ្វីដែលគេស្លេះចោលនៅមានច្រើនឥតគណនា គេអាចនិយាយថា ។ល។ និង ។ល។

## ១៣. ខណ្ឌ ( ។) ឬហៅម្យ៉ាងទៀតថា **វបះ** ( កុំច្រឡំនឹង ល្បះ)

ជាសញ្ញាមួយដែលគេប្រើសម្រាប់រាំងប្រយោគ ឬរាំងសង្កាត់នៃសេចក្ដីនីមួយៗ ឱ្យដាច់ស្រឡះពីគ្នា គឺថា កាលណាប្រយោគមួយចប់សេចក្ដីហើយ គេត្រូវដាក់ខណ្ឌសញ្ញា ( ។) បែបនេះសិន មុននឹងបន្តទៅប្រយោគមួយទៀត ។ **ខណ្ឌ** អាចជួយឱ្យគេយល់សេចក្ដីនៅក្នុងអត្ថបទបានច្បាស់ ដូចការអាន ឬការសរសេរដោយមានការដកឃ្លា ឬប្រើក្បៀស ឬចំណុចក្បៀស ដែរ ។

កាលបើការសរសេរត្រូវប្ដូរទៅវគ្គ( កថាខណ្ឌ)ថ្មី គេមិនត្រូវសរសេរបន្តនៅលើបន្ទាត់ដដែលតែមួយទេ ប៉ុន្តែគេត្រូវដូរទៅបន្ទាត់ថ្មី ។ ក្នុងករណីនេះគេនិយាយថា "ខណ្ឌចុះបន្ទាត់ ឬ ខណ្ឌចាប់ដើមបន្ទាត់" ។ ខណ្ឌចុះបន្ទាត់នេះគេប្រើសម្រាប់បញ្ចប់ប្រយោគនីមួយៗនៃពាក្យកាព្យផងដែរ ។ ឧទាហរណ៍ ៖

### ក/ ការចងក្រងប្រយោគដើម្បីពិពណ៌នា :

ចងក្រងអត្ថបទមិនអាចធ្វើបានដោយស្រួលៗទេ ។ គេត្រូវក្ដាប់ន័យឱ្យបាន ចេះពាក្យពេចន៍និងសំនួនវោហារសព្ទឱ្យបានទូលំទូលាយ ចងក្រងពាក្យឱ្យទៅជាឃ្លោងឃ្លា និឱ្យទៅជាប្រយោគ ។ គេត្រូវគោរពអក្ខរាវិរុទ្ធរបស់ពាក្យត្រូវចេះប្រើខណ្ឌសញ្ញាឱ្យបានត្រឹមត្រូវ ។ ឧទាហរណ៍ ៖

ព្រះគណបតីទ្រង់ព្រះសិតការណ៍ ជាសញ្ញានៃការយល់ព្រមចំពោះលក្ខខណ្ឌខាងក្រោយនេះ ។ បន្ទាប់មក ឬសីវ្យាសៈក៏ចាប់ផ្ដើមថ្វាថ្លែងនិទានអំពី

រឿងមហាភារតៈនោះដូចបានត្រៀមទុក ។ ជូនកាលមហាឫសីចងក្រងឃ្លាកាព្យខ្លះដ៏សែនស្មុគស្មាញ ដែលធ្វើឱ្យព្រះគណបតីត្រូវបង្អង់មួយភ្លែតសិនដែរ ដើម្បីចាប់ន័យឱ្យបាន ហើយឫសីវ្យាសៈក៏ឆ្លៀតយកចន្លោះនៃឱកាសនោះដើម្បីចងក្រងឃ្លាកាព្យជាច្រើនទុកក្នុងអារម្មណ៍ឱ្យរួចជាស្រេច ។ គឺយ៉ាងដូច្នេះឯងហើយ ដែលរឿងមហាភារតៈត្រូវបានទទួលការសរសេរកត់ត្រា តាមការពោលជាពាក្យពេចន៍ចេញមកដោយមហាឥសីវ្យាសៈ ។

អស់កាលដ៏យូរលង់មុននឹងកើតមានការបោះពុម្ពរឿងនេះឡើង មានតែខួរក្បាលអ្នកប្រាជ្ញប៉ុណ្ណោះទេដែលជាទីទុកដាក់រក្សាសៀវភៅ ។ ដំបូង ឫសីវ្យាសៈបង្រៀនមហាវីរកថានេះដល់បុត្ររបស់ព្រះអង្គ គឺឫសីសុកៈ ។ ក្រោយមក ព្រះអង្គបានពង្រីកការសិក្សារឿងនេះដល់សិស្សគណរបស់ព្រះអង្គជាច្រើននាក់ទៀត ។ បើកុំតែបានប៉ុណ្ណេះ ម្ល៉េះសមមនុស្សយើងជំនាន់ក្រោយៗមិនអាចបានឃើញសៀវភៅរឿងដ៏សំខាន់នេះទេ ។ (រឿងមហាភារតៈ) ។

**ខ/ ការបញ្ចប់បទកាព្យនីមួយៗ ;** ឧទាហរណ៍ ៖

**បទកាកគតិ**

ត្រូវចេះស្គាល់ **មួយ** ដើម្បីទុកជួយ **ពីរ** និងត្រួតត្រា
**បី** តាមរយៈ ធមិ **បួន** ប្រការ **ឆ្នាំ** ជាតណ្ហា
ជម្នះឱ្យបាន ។

ស្ទាត់នឹង **ឆ្នាំមួយ** ហើយកុំលើកស្ទួយ **ឆ្នាំពីរ** ជាថ្កាន
ត្រូវតមទល់ទប់ ត្រូវឈប់ខកខាន កុំធ្វើកល្យាណ
នឹងរឿងអាស្រូវ ។[១]

១- ច្បាប់ព្រះវិទូរ. ទស្សនវិជ្ជានៃអភិសមាចារ. ទំព័រ ៣០-៣១ (ធន់ ហ៊ិន) ។



**បទព្រហ្មគីតិ**

មិនដែលមានទេព្ដា ជួយជនណាអន់អប្រិយ
ទុច្ចរិតអន្យតិរ្ថិយ ធ្វើឫស្ដីតាមទំនើង ។
គេអាចស្គាល់មាសសុទ្ធ បានដោយដុតសាកនឹងភ្លើង
ស្គាល់ពូជពង្សថ្កុំថ្កើង តាមឥរិយាបទថ្លៃថ្នូរ ។[១]

**បទពាក្យ៧**

ពោលគឺបោះបង់ឧបាទាន កុំឱ្យកើតមានសោះតែម្ដង
ពីព្រោះវាជាខ្សែចំណង ដែលចងយើងភ្ជាប់ទៅតណ្ហា ។
តណ្ហាជាឫសគល់កំហឹង លែងឱ្យរឹងប៉ឹងក្នុងចិន្ដា
សតិវិបល្លាសជាផ្លែផ្កា អន្ដរាយរូបានៅចុងផុត ។[២]

**បទបន្ទោលកាក**

ក្សត្រត្រូវរៀបគ្រឿងសក្ការ បូជាទេព្ដា ឱ្យទៀងជាប្រក្រតី ។
ប្រាជ្ញណាប្រាថ្នាអ្វីៗ ដែលជាលោកិយ ទោះបីរស់ក៏ដូចស្លាប់ ។
ដាក់ទានបាយទឹកជាស- ប្បុរសធមិគាប់ ជាទម្លាប់អភិជន ។
មាតាជាអ្នកមានគុណ ប្រសើរពេកពន់ សែនធ្ងន់លើសទាំងផែនដី ។
ឯអ្នកខ្ពង់ខ្ពស់ពិសី ហួសសូគិាល័យ គឺបិតាយើងនោះហោង ។[៣]

១- ច្បាប់ព្រះពិទូរ. ទស្សនវិជ្ជានៃអភិសមាចារ. ទំព័រ ៤៧ (ធន់ ហ៊ិន) ។
២- ច្បាប់ព្រះក្រឹស្ណា. ទស្សនវិជ្ជានៃអភិសមាចារ. ទំព័រ ៦៧ (ធន់ ហ៊ិន) ។
៣- ច្បាប់ព្រះធម្មៈ ទស្សនវិជ្ជានៃអភិសមាចារ ទំព័រ ១៨ (ធន់ ហ៊ិន) ។

## បទភុជង្គលីលា

ចៅអើយ! អ្វីទៅដែលល្អ ជាកុសលធមិ ប្រសើរបំផុត ។
គឺកាន់យុត្តិធមិបរិសុទ្ធ វៀរចាកឱ្យផុត ពីគ្រឿងស្រវឹង ។
តមកុំស៊ីសាច់ឈាមឆ្អឹង កុសលបីហ្នឹង ជាព្រហ្មចារ្យ ។
ធម្មៈ. អត្ថៈ ជាសារ កាមៈ ជាអាទិ៍ គេត្រូវប្រព្រឹត្ត ។
ក្នុងផ្នែកដើមនៃជីវិត គឺត្រូវគួរគិត ប្រមូលធនទ្រព្យ ។
យុត្តិធមិដ៏សែនគួរគាប់ ក៏ចាប់ផ្ដើមជាប់ ពីពេលនោះមក ។[1]

## ១៤. ខណ្ឌចប់ ( ៕ )

ដូចមានជាឈ្មោះរបស់វានេះស្រាប់ សញ្ញាខណ្ឌចប់សម្រាប់សម្គាល់ថាអត្ថបទមួយនេះឬរឿងមួយនេះត្រូវគេបញ្ចប់ជាស្ថាពរត្រឹមនេះឯង គឺលែងមានអ្វីបន្តទៀតឡើយ ។ (មើល ខណ្ឌបរិយោសាន ឬ គោមូត្រ ក្នុងចំណុច ១៨ ខាងក្រោមនេះ) ។

## ១៥. អាទិសង្កេត (.)

គឺជាចំណុចមួយដែលគេប្រើសម្រាប់ដាក់ជាប់នឹងអក្សរ (ជាព្យញ្ជនៈទីមួយរបស់ពាក្យ) ដែលគេត្រូវការសរសេរកាត់ ។ ឧទាហរណ៍ :

អ. ស. ប.(អង្គការសហប្រជាជាតិ) ; ស. រ. អា. (សហរដ្ឋអាមេរិក) ; ឯ. ឧ.(ឯកឧត្ដម); គ. ជ. ប. (គណៈកម្មការជាតិរៀបចំការបោះឆ្នោត), ។ល។

គេប្រើសញ្ញាអាទិសង្កេតនេះជាមួយនឹងលេខរៀង ឬជាមួយនឹងលំដាប់ព្យញ្ជនៈ ដើម្បីរៀបរាប់នូវលំដាប់លំដោយនៃប្រធានបទរង (sous-titres) ដែលគេនឹងត្រូវធ្វើអត្ថាធិប្បាយជាបន្តបន្ទាប់ទៅ ។ ឧទាហរណ៍ ៖

---

១- ច្បាប់ព្រះភិក្ខុៈ ទស្សនវិជ្ជានៃអភិសមាចារ ទំព័រ ១១៩-១២០ (ធន់ ហ៊ិន) ។



១. អំពីការប្រើវណ្ណយុត្តិ (.............................)

២. អំពីការប្រើខណ្ឌសញ្ញា (.............................)

៣. អំពីព្យាង្គរាយ និង ព្យាង្គតម្រួត (......................) ។ល។

**សម្គាល់** .- ក្នុងការសរសេរកាត់ដោយប្រើតែតួអក្សរ គេត្រូវដាក់សញ្ញាអាទិសង្កេតនៅខាងស្ដាំជាប់នឹងតួអក្សរនីមួយៗជាដាច់ខាត ដូចជា :

អ.ស.ប.. គ.ជ.ប.. ឯ.ឧ.. ម.ស.ប.ភ. ។ល។ ប៉ុន្តែគេមិនត្រូវសរសេរជា : អ ស ប . ឬ អ.ស.ប, គ.ជ.ប, ឯ.ឧ បែបនេះជាដើមទេ ។

សញ្ញាខ្លះដែលខ្មែរយើងប្រើពីសម័យមុន ប៉ុន្តែឥឡូវលែងប្រើគឺ ៖

## ១៧. កុក្កុដនេត្រ ឬ ភ្នែកមាន់ ( ๏ )

សញ្ញាកិក្កុដនេត្រនេះត្រូវបានខ្មែរយើងពីសម័យមុនៗប្រើសម្រាប់ផ្ដើមការសរសេរអត្ថបទ ឬរឿងអ្វីមួយ ឬជំពូកនីមួយៗ ប៉ុន្តែមកដល់សម័យបច្ចុប្បន្ននេះ ខ្មែរយើងបានបោះបង់ការប្រើប្រាស់វាជាស្ថាពរទៅហើយ ។

## ១៨. ខណ្ឌបរិយោសាន ឬ គោមូត្រ ( ៚ )

ជាគូផ្ទុយគ្នានឹងសញ្ញាកុក្កុដនេត្រ សញ្ញាខណ្ឌបរិយោសានត្រូវបានខ្មែរយើងនៅនាសម័យបុរាណប្រើសម្រាប់បញ្ចប់រឿងមួយជាស្ថាពរ ពោលគឺនៅចុងបញ្ចប់នៃរឿងដែលគេបាននិទានក្នុងមួយសៀវភៅឬក្នុងនោះឯង ។ យើងបានប្រើជំនួសជាស្ថាពរនូវសញ្ញាខណ្ឌចប់ ( ៕ ) នេះវិញ ។ ប៉ុន្តែការប្រើគោមូត្រនេះក៏មិនមែននៅក្នុងការបំភ្លេចចោលទាំងស្រុងដែរ ប្រសិនបើគេចង់ប្រើ ។

**សម្គាល់** : មុននឹងដាក់ "។" អ្នកប្រាជ្ញខ្មែរយើងឱ្យដកឃ្លា ដើម្បីកុំឱ្យច្រឡំភ្នែក ព្រោះថា "។" មានទំហំប៉ុនតួព្យញ្ជនៈ រួចដកឃ្លាម្ដងទៀត សិមបន្តប្រយោគថ្មី ។ ត្រូវដកឃ្លាដូចគ្នាដែរចំពោះ ខណ្ឌចប់ និង ខណ្ឌបរិយោសាន ។